WWF Greater Mekong

D13 Thang Long
International Village
Cau Giay District
IPO Box 151
Hanoi, Vietnam

Tel: +84 4 3719 3049
Fax: +84 4 3719 3102
panda.org/greatermekong

for a living planet®

សេចក្តីប្រកាសសារពត៌មាន សូមកុំចេញផ្សាយមុនម៉ោង១១.៥៩នាទីយប់នៃថ្ងៃទី១៩មិថុនា២០១៣

# ទំនប់វារីអគ្គីសនីអាចជាសញ្ញាមរណៈសម្រាប់ត្រីរាជ

ទីក្រុងបាងកក ប្រទេសថៃ៖ យោងតាមការសិក្សាថ្មីមួយដែលឧបត្ថមដោយ WWF ការសាងសង់ទំនប់វារីអគ្គីសនីនៅលើដងទន្លេមេគង្គបែបខាងក្រោមអាចជាកត្តាគំរាមកំហែងថ្មីមួយចំពោះការរស់នៅរបស់ត្រីរាជនៅក្នុងទន្លេមេគង្គ ដែលជាត្រីទឹកសាបទំហំធំជាងគេដ៏កម្រមួយប្រភេទនៅលើពិភពលោក។

ការសិក្សានេះបង្ហាញពត៌មានស្តីអំពីស្ថានភាពរបស់ត្រីរាជ រួមមាន ចំនួន របាយ កត្តាគំរាមកំហែង និងវិធានការចាំបាច់ក្នុងការទប់ស្កាត់កុំឲ្យសត្វនេះវិនាសបាត់បង់។ គេនៅមិនទាន់ដឹងអំពីចំនួនពិតប្រាកដរបស់សត្វនេះទេ ប៉ុន្តែគេជឿជាក់ថាត្រីរាជវ័យជំទង់ ដែលកំពុងរស់នៅក្នុងទន្លេមេគង្គអាចមានចំនួនប្រមាណពីររយក្បាល។

យោងតាមការសិក្សា ការសាងសង់ទំនប់វារីអគ្គីសនីសាយាបូរីនៅលើដងទន្លេមេគង្គនៅប៉ែកខាងជើងប្រទេសឡាវ នឹងក្លាយជារនាំងឧបសគ្គសម្រាប់ការហែលឆ្លងរបស់ត្រីរាជ និងបង្កគ្រោះថ្នាក់ឲ្យសត្វនេះទទួលរងការផុតពូជ។ ត្រីរាជអាចមានប្រវែងរហូតដល់បីម៉ែត្រ ហើយអាចមានទម្ងន់រហូតដល់ ៣០០ គីឡូក្រាម។

លោកបណ្ឌិត ហ្សេប ហូហ្គិន ជាអ្នកនិពន្ធរបាយការណ៍ និងជាសាស្ត្រាចារ្យផ្នែកស្រាវជ្រាវនៃសាកលវិទ្យាល័យនីវាដាមានប្រសាសថា៖ “ត្រីដែលមានទំហំធំប៉ុនត្រីរាជនឹងមិនអាចហែលឆ្លងកាត់រនាំងដ៏ធំប៉ុនទំនប់នេះដើម្បីធ្វើដំណើរទៅកាន់ជម្រកពងកូនរបស់វានៅប៉ែកខាងលើទន្លេបានទេ។”
“ពពួកសត្វដែលមានទំហំធំត្រូវការផ្ទៃទឹកទំហំធំ ហើយគ្មានការកាត់ផ្តាច់ ដើម្បីហែលឆ្លងកាត់ ហើយត្រូវការរស់នៅក្នុងបរិស្ថានទឹកដែលមានល័ក្ខខ័ណ្ឌគុណភាព និងលំហូរពិសេស ដើម្បីពងកូន រកចំណី និងចិញ្ចឹមកូន។”

ចំនួនត្រីរាជនៅក្នុងទន្លេមេគង្គបានទទួលរងនូវការធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរបណ្តាលមកពីការនេសាទហួសកំរិត ការបំផ្លាញទីជម្រក និងការសាងសង់ទំនប់វារីអគ្គីសនីនៅលើដៃទន្លេមេគង្គ។ នៅក្នុងទន្លេ មុន ដែលជាដៃទន្លេមេគង្គធំជាងគេ ទំនប់វារីអគ្គីសនីមួយបានធ្វើឲ្យរាំងស្ទះដល់ការហែលឆ្លងកាត់របស់ត្រីរាជ ហើយបានបំបែកហ្វូងដែលរស់នៅក្នុងដៃទន្លេនេះ ឲ្យឃ្លាតឆ្ងាយពីចំនួនត្រីដ៏ទៃទៀតដែលរស់នៅក្នុងអាងទន្លេមេគង្គ។ ការសិក្សាបានបង្ហាញថាទំនប់សាយាបូរីដ៏ចម្រូងចម្រាស់មួយនេះ អាចបញ្ឈប់ និងធ្វើឲ្យរាំងស្ទះការពងកូន ហើយធ្វើឲ្យអត្រាមរណៈកើនឡើង ប្រសិនបើត្រីរាជត្រូវហែលឆ្លងកាត់កង្ហាទួរប៊ីន ដែលជាផ្នែកនៃប្រព័ន្ធទំនប់វារីអគ្គីសនី។

WWF for a living planet®

លោកបណ្ឌិត ហេ្សប ហូហ្គិន បានបន្ថែមថា៖ “តំបន់នៃគម្រោងសាងសង់ទំនប់សាយាបូរីជាច្រកឆ្លងកាត់សម្រាប់ត្រីរាជធ្វើការផ្លាស់ទី ជាពិសេសគឺពពួកត្រីពេញវ័យ ដែលធ្វើដំណើរតាមច្រកនេះចេញពីតំបន់ព្រៃលិចទឹកឆ្ពោះទៅកាន់តំបន់ដែលជាជម្រកសម្រាប់ពងកូនរបស់ពួកវានៅផ្នែកខាងលើទន្លេ។” លោកបានបន្តទៀតថា៖ “ត្រីរាជទាំងនេះក៏អាចពងកូននៅត្រង់ទីតាំង ដែលគេកំណត់យកជាតំបន់សាងសង់ទំនប់វារីអគ្គីសនីនេះផងដែរ។”

នាកិច្ចប្រជុំនៃគណៈកម្មការទន្លេមេគង្គកាលពីឆ្នាំ២០១១ បណ្តារដ្ឋមន្ត្រីបរិស្ថាន និងធនធានទឹក បានឯកភាពគ្នាលើការពន្យាសេចក្តីសម្រេចចិត្តចំពោះការសាងសង់ទំនប់សាយាបូរី ដើម្បីរង់ចាំឲ្យមានការសិក្សាស្តីអំពីហេតុប៉ះពាល់បរិស្ថានសិន។ កិច្ចព្រមព្រៀងគ្នានេះត្រូវបានគេទាត់ចោលនៅពេលដែលភាគីឡាវបានសម្រេចដាក់ឲ្យមានដំណើរការសាងសង់ទំនប់នេះ។

ការរិះគន់បានកើនឡើងយ៉ាងសន្ធឹកសន្ធាប់លើគម្រោងសាងសង់ទំនប់សាយាបូរីដែលមានទឹកប្រាក់ចំនួនបីកោដកន្លះនេះ ដើម្បីបង្ហាញពីការព្រួយបារម្ភស្តីអំពីកង្វះខាតនូវពត៌មានដ៏ធ្ងន់ធ្ងរ ព្រមទាំងបរាជ័យជាច្រើនក្នុងការពន្យល់អំពីហេតុប៉ះពាល់ ដែលនឹងកើតចេញពីគម្រោងនេះ ជាពិសេសពាក់ព័ន្ធនឹងផ្នែកជលផល និងលំហូរដីល្បាប់។

ក្រុមហ៊ុនពយរីរបស់ហ្វាំងឡង់ ដែលជាភ្នាក់ងារផ្តល់ប្រឹក្សាសម្រាប់ការសាងសង់បានអះអាងថាគេអាចសាងសង់ផ្លូវសម្រាប់ឲ្យត្រីធ្វើចរាចរកាត់តាមច្រកកង្ហាទួរបីននៃប្រព័ន្ធទំនប់ ដើម្បីឲ្យពួកវាហែលឡើងទៅផ្នែកខាងលើ និងចុះផ្នែកខាងក្រោមទន្លេ។ ប៉ុន្តែកន្លងមក មិនទាន់មានការបង្ហាញថាការអនុវត្តន៍វិធីសាស្ត្របែបនេះទទួលបានជោគជ័យនៅឡើយទេ។

លោកបណ្ឌិត អេរិក ប៉ែរិន នៃ World Fish Centre បាននិយាយថា៖ “គេមិនអាចដឹងបានថាតើផ្លូវដណ្តើរសម្រាប់ត្រីធ្វើចរាចរមានប្រសិទ្ធភាពឫអត់ប្រសិនបើគ្មានការសិក្សា អំពីប្រភេទត្រីដែលប្រើប្រាស់ផ្លូវបែបនេះ លទ្ធភាពហែលរបស់វា និងចរន្តទឹក ដែលនឹងស្រូបយកត្រីទាំងនេះចូលទៅក្នុងទ្វារទំនប់ ឲ្យបានច្បាស់លាស់ទេនោះ។”
“គេត្រូវធ្វើការស្រាវជ្រាវបន្ថែមទៀតដើម្បីឲ្យមានភាពប្រាកដប្រជាថាការធ្វើចរាចរផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀតមានប្រសិទ្ធភាព។”

ត្រីរាជធ្លាប់មានវត្តមាននៅពាសពេញអាងទន្លេមេគង្គទាំងមូល ក្នុងនោះអាចរាប់បញ្ចូលទាំងនៅភូមា និងប៉ែកនារតីនៃប្រទេសចិនផងដែរ ហើយចំនួនរបស់វាមានច្រើនរហូតទល់ដើមឆ្នាំ១៩០០។ ចាប់តាំងពីក្រោយឆ្នាំនេះ ចំនួនរបស់វាបានចាប់ផ្តើមធ្លាក់ចុះ ហើយបច្ចុប្បន្នត្រីរាជមានវត្តមានតែនៅក្នុងទន្លេមេគង្គ និងដៃទន្លេនេះ ក្នុងប្រទេសកម្ពុជា ឡាវ និងថៃប៉ុណ្ណោះ។

WWF for a living planet®

តួលេខនៃផលចាប់ក៏ជាភ័ស្តុតាងបង្ហាញពីការធ្លាក់ចុះផងដែរ ដែលក្នុងនោះបរិមាណនៃការចាប់បានធ្លាក់ចុះពីចំនួនរាប់ពាន់ក្បាលនៅចុងឆ្នាំ១៨៨០ មកនៅត្រឹមចំនួនរាប់សិបក្បាលប៉ុណ្ណោះក្នុងឆ្នាំ១៩៩០ ហើយមកទល់ពេលថ្មីៗនេះ ការចាប់មានតែចំនួនប៉ុន្មានក្បាលប៉ុណ្ណោះ។ បើទោះបីជាប្រទេសថៃ ឡាវ និងកម្ពុជាមានច្បាប់ និងវិធានការការពារ តួយ៉ាងដូចជាការហាមប្រាមដាច់ខាតចំពោះការនេសាទសត្វនេះនៅក្នុងប្រទេសថៃ និងកម្ពុជាក៏ដោយ ត្រីរាជនៅតែទទួលរងការចាប់ដោយខុសច្បាប់ និងត្រូវគេចាប់បានដោយចៃដន្តនៅពេលនេសាទត្រីប្រភេទផ្សេង។

លោកបណ្ឌិត ហ្សេប ហូហ្គិន បាននិយាយថា៖ “គេត្រូវចាត់វិធានការតាមដានឲ្យជិតដល់ចំពោះសកម្មភាពនេសាទដើម្បីធានាថាត្រីរាជមិនត្រូវបានក្លាយជាគោលដៅរបស់អ្នកនេសាទទេ។”
“ដូចគ្នានេះដែរ គេក៏ត្រូវតែតាមដានការចាប់បានដោយចៃដន្ត ពីព្រោះវាជាប្រភពពត៌មានដ៏សំខាន់មួយស្តីអំពីរបាយ ប្រវត្តិនៃការរស់នៅ និងចំនួនរបស់សត្វនេះ។”

ការសិក្សាបានកំណត់នូវវិធានការការពារសត្វនេះកុំឲ្យបាត់បង់ រួមមានការចាត់វិធានការបន្ទាន់ដើម្បីការពារតំបន់ដែលជាច្រកសម្រាប់ត្រីរាជហែលឆ្លងកាត់ និងទីជម្រកសំខាន់ៗរបស់វា បង្កើនកិច្ចសហប្រតិបត្តិការណ៍អន្តរជាតិតួយ៉ាងដូចជាការបង្កើតផែនការគ្រប់គ្រងអាងទន្លេទាំងមូលពីព្រោះត្រីរាជមានរស់នៅក្នុងទន្លេដែលហូរកាត់តាមប្រទេសច្រើន។

លោកបណ្ឌិត លីហ្វេង លី ជានាយកកម្មវិធីទឹកសាបសាកលនៃអង្គការ WWF បាននិយាយថា៖ “ត្រីរាជជានិមិត្តរូបអតិបតេយ្យភាពនៃប្រព័ន្ធអេកូឡូស៊ីនៃអាងទន្លេមេគង្គ ដោយហេតុថាសត្វនេះជាប្រភេទសត្វងាយទទួលរងគ្រោះថ្នាក់ដោយសារសកម្មភាពនេសាទ និងការប្រែប្រួលនៃបរិស្ថានទន្លេ។ ស្ថានភាពរបស់ត្រីរាជជាកត្តាមួយចង្អុលបង្ហាញអំពីគុណភាពនៃអាងទន្លេទាំងមូល ហើយការស្តារឲ្យសត្វនេះឲ្យមានចំនួនច្រើនឡើងវិញជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ការគ្រប់គ្រងអាងទន្លេមេគង្គប្រកបដោយនិរន្តរភាព។

“គេអាចជួយសង្គ្រោះត្រីរាជឲ្យរួចផុតពីការបាត់បង់បាន ប៉ុន្តែអ្វីដែលបច្ចុប្បន្នគ្មានគឺវិធានការសង្គ្រោះនោះទាមទារឲ្យមានឆន្ទៈប្តេជ្ញាចិត្តខ្ពស់ពីសំណាក់ប្រទេសទាំងអស់នៃមេគង្គបែកខាងក្រោម ក៏ដូចជាឆន្ទៈពីសំណាក់អង្គការអន្តរជាតិ និងភាគីអ្នកផ្តល់ជំនួយនានាផងដែរ។”

**For further information:**
Sarah Bladen, Communications Director, WWF Greater Mekong, tel: +844 37193049 ext 164.
mobile: +84 1224 223 760 sarah.bladen@wwfgreatermekong.org

**Downloads:**
- The report can be downloaded at: http://awsassets.panda.org/downloads/mgc_report_june2013.pdf
- Download photos of the Mekong giant catfish at: http://www.mediafire.com/?fnv5v1badms4u

Please credit all photos: © Zeb Hogan. Captions are available for download at the above URL.

**About WWF**

WWF is one of the world's largest and most respected independent conservation organizations, with over 5 million supporters and a global network active in over 100 countries. WWF's mission is to stop the degradation of the earth's natural environment and to build a future in which humans live in harmony with nature, by conserving the world's biological diversity, ensuring that the use of renewable natural resources is sustainable, and promoting the reduction of pollution and wasteful consumption.